# ព័ត៌មានមិនត្រឹមត្រូវអំពីថ្នាំបង្ការ



នៅក្នុងសម័យកាលឌីជីថលនាពេលឥឡូវនេះ ព័ត៌មាននានាផ្សព្វផ្សាយយ៉ាងលឿន។ គួរឱ្យសោកស្តាយ ព័ត៌មានមិនត្រឹមត្រូវក៏ផ្សព្វផ្សាយយ៉ាងលឿនផងដែរ។ ការយល់ច្រឡំផ្សេងៗអំពីថ្នាំបង្ការអាចចាប់ផ្តើមពីពាក្យចចាមអារ៉ាមសាមញ្ញមួយ ការយល់ខុស ឬសូម្បីតែការផ្សព្វផ្សាយព័ត៌មានមិនពិតដោយចេតនាផងដែរ។

ព័ត៌មានមិនត្រឹមត្រូវនេះអាចឈានទៅជាការភ័យខ្លាច និងការភ័ន្តច្រឡំ ហើយនៅក្នុងករណីខ្លះបានឈានទៅជាមានការផ្ទុះឡើងនៃជំងឺមួយដែលពួកយើងគ្រប់គ្រងបានត្រឹមត្រូវហើយនោះ ដូចជាជំងឺកញ្ជ្រឹលជាដើម។ មកបញ្ជាក់អំពីការពិតឱ្យបានច្បាស់លាស់ ដោយបំបាត់ជំនឿមិនពិតជាទូទៅមួយចំនួនអំពីថ្នាំបង្ការវិញ។

**ចំណុចមិនពិត៖ ថ្នាំបង្ការទាំងឡាយបណ្តាលឱ្យមានបញ្ហាការលូតលាស់ផ្នែកយល់ដឹង (Autism)។**
***ការពិត៖*** មិនមានភស្តុតាងផ្នែកវិទ្យាសាស្ត្រណាមួយដែលថាថ្នាំបង្ការទាំងឡាយបណ្តាលឱ្យមានបញ្ហាការលូតលាស់ផ្នែកយល់ដឹងនោះទេ។ ជំនឿមិនពិតនេះបានចាប់ផ្តើមឡើងដោយការសិក្សាមួយដែលមានកំហុសនៅក្នុងឆ្នាំ 1998 ហើយបានដកយកទៅវិញដោយសារតែភាពខុសឆ្គងធ្ងន់ធ្ងរ និងបញ្ហាផ្នែកក្រមសីលធម៌ នាពេលក្រោយមក។ ចាប់តាំងពីពេលនោះមក ការសិក្សាស្រាវជ្រាវដ៏ធំធេងជាច្រើនដែលពាក់ព័ន្ធទៅនឹងកុមាររាប់លាននាក់នៅទូទាំងពិភពលោកមិនបានរកឃើញការទាក់ទងរវាងថ្នាំបង្ការទាំងឡាយ និងបញ្ហាការលូតលាស់ផ្នែកយល់ដឹងនោះទេ។

**ចំណុចមិនពិត៖ ភាពស៊ាំបែបធម្មជាតិគឺប្រសើរជាងភាពស៊ាំដែលថ្នាំបង្ការផ្តល់ឱ្យ។**
***ការពិត៖*** ការឆ្លងជំងឺមួយអាចផ្តល់ភាពស៊ាំដល់អ្នកនៅពេលខ្លះ ប៉ុន្តែចំណុចនេះគឺមិនជាប់លាប់ឡើយ និងអាចមានហានិភ័យកម្រិតធ្ងន់ធ្ងរចំពោះសុខភាព ទៀតផង។ ឧទាហរណ៍ ការកើតជំងឺអុតស្វាយអាចធ្វើឱ្យអ្នកស៊ាំនឹងជំងឺពេញមួយជីវិត ប៉ុន្តែការធ្វើបែបនេះក៏អាចឈានទៅកាន់ផលវិបាកកម្រិតធ្ងន់ធ្ងរផ្សេងៗ ដូចជាដំបៅក្លាយនៅលើស្បែក ឬ pneumonia (ជំងឺរលាកសួត) ជាដើម។ ផ្ទុយទៅវិញ ថ្នាំបង្ការទាំងឡាយផ្តល់នូវប្រព័ន្ធការពារប្រហាក់ប្រហែលនឹងគ្នានេះ ដោយមិនមានហានិភ័យនៃការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរនោះទេ។




**ចំណុចមិនពិត៖ ថ្នាំបង្ការទាំងឡាយមានផ្ទុកគ្រឿងផ្សំដែលបង្កគ្រោះថ្នាក់។**
***ការពិត៖*** ថ្នាំបង្ការទាំងឡាយមានផ្ទុកគ្រឿងផ្សំផ្សេងៗដែលត្រូវការដើម្បីរក្សាថ្នាំទាំងនេះឱ្យនៅតែមានប្រសិទ្ធិភាព និងមានសុវត្ថិភាព។ សារធាតុផ្សំមួយចំនួនប្រហែលជាគួរឱ្យខ្លាច ដូចជា formaldehyde (សារធាតុម៉្យាងដែលបានមកពីការដាក់បញ្ចូលអុកស៊ីសែនទៅក្នុងមេតាណុល) និង mercury (សារធាតុបារត) ជាដើម ប៉ុន្តែបរិមាណសារធាតុ formaldehyde នៅក្នុងថ្នាំបង្ការគឺមានតិចខ្លាំងណាស់។ ជាការពិតនោះ បរិមាណនេះគឺមានតិចជាងបរិមាណដែលរាងកាយបង្កើតឡើងដោយធម្មជាតិក្នុងមួយថ្ងៃៗ ទៀតផង។ ថ្នាំបង្ការភាគច្រើនមិនមានសារធាតុបារតនោះទេ ហើយមានការដក thimerosal ដែលជាសារធាតុបារតមួយបែបនោះ ចេញពីថ្នាំបង្ការសម្រាប់ពេលកុមារភាពទាំងអស់ នៅក្នុងឆ្នាំ 2001 ផងដែរ។ នៅពេលដាក់ប្រើប្រាស់ សារធាតុបារតនេះជួយទប់ស្កាត់ការដុះមេរោគ និងផ្សិតនៅក្នុងថ្នាំបង្ការដែលមានចាក់ជូនជាលំដាប់ច្រើនដូស។ បន្ថែមពីលើនេះ ថ្នាំបង្ការទាំងឡាយត្រូវបានធ្វើតេស្ត និងតាមដានជាបន្តបន្ទាប់ចំពោះផ្នែកសុវត្ថិភាព ដោយអ្នកវិទ្យាសាស្ត្រ និងអ្នកជំនាញផ្នែកសុខភាព។

# ព័ត៌មានមិនត្រឹមត្រូវ អំពីថ្នាំបង្ការ



**ចំណុចមិនពិត៖ ថ្នាំបង្ការទាំងឡាយអាចធ្វើឱ្យអ្នកកើតជំងឺដែលថ្នាំបង្ការនោះផលិតឡើងដើម្បីទប់ស្កាត់។**
***ការពិត៖*** ថ្នាំបង្ការភាគច្រើនមានផ្ទុកបំណែកមេរោគដែលមិនអាចធ្វើឱ្យអ្នកឈឺនោះទេ។ ថ្នាំបង្ការមួយចំនួនមានមេរោគដែលបានធ្វើឱ្យចុះខ្សោយ ឬមេរោគដែលនៅរស់ ប៉ុន្តែមេរោគទាំងនេះគឺមានភាពទន់ខ្សោយពេកក្នុងការបង្កឱ្យមានជំងឺ។ ផ្ទុយទៅវិញ មេរោគបែបនេះបង្រៀនប្រព័ន្ធភាពស៊ាំរបស់អ្នកឱ្យដឹងអំពីវិធីទប់ទល់ជាមួយនឹងមេរោគពិតប្រាកដ ប្រសិនបើមេរោគនោះបង្ហាញខ្លួន។

**ចំណុចមិនពិត៖ ថ្នាំបង្ការទាំងឡាយធ្វើឱ្យប្រព័ន្ធភាពស៊ាំរបស់អ្នកចុះខ្សោយ។**
***ការពិត៖*** ជាការពិតនោះ ថ្នាំបង្ការទាំងឡាយបង្ហាត់ប្រព័ន្ធភាពស៊ាំរបស់អ្នកឱ្យខ្លាំងឡើង។ ដោយការណែនាំមេរោគដែលមិនមានគ្រោះថ្នាក់ចូលមក ប្រព័ន្ធភាពស៊ាំរបស់អ្នករៀនអំពីវិធីការពារប្រឆាំងនឹងមេរោគនោះ។ ការធ្វើបែបនេះនឹងឱ្យរាងកាយរបស់អ្នកដឹងថាត្រូវធ្វើយ៉ាងណា ប្រសិនបើអ្នកជួបប្រទះនឹងមេរោគពិតប្រាកដនៅថ្ងៃណាមួយ។

**ចំណុចមិនពិត៖ ខ្ញុំមិនត្រូវការថ្នាំបង្ការនោះទេ ពីព្រោះភាពស៊ាំជាហ្វូង (Herd Immunity) នឹងការពារខ្ញុំ។**
***ការពិត៖*** ភាពស៊ាំជាហ្វូងដំណើរការទៅបានតែប៉ុណ្ណោះនៅពេលដែលមនុស្សមួយភាគធំបានទទួលចាក់ថ្នាំបង្ការ ហើយការពារអ្នកដែលមិនអាចចាក់ថ្នាំបង្ការបាន ដូចជាទារកទើបនឹងកើត ឬអ្នកដែលមានបញ្ហាសុខភាពជាក់លាក់ផ្សេងៗ ជាដើម។ ប្រសិនបើមនុស្សជាច្រើនជ្រើសរើសមិនចាក់ថ្នាំបង្ការទេនោះ ភាពស៊ាំជាហ្វូងមិនដំណើរការឡើយ ហើយធ្វើឱ្យមនុស្សគ្រប់រូបប្រឈមនឹងហានិភ័យ រួមទាំងអ្នកដែលងាយស្រួលនឹងរងគ្រោះបំផុត ផងដែរ។

**ចំណុចមិនពិត៖ ថ្នាំបង្ការទាំងឡាយមានមីក្រូឈីប (Microchips) ដែលតាមដានមនុស្ស។**
***ការពិត៖*** ថ្នាំបង្ការទាំងឡាយប្រាកដណាស់មិនមានមីក្រូឈីប ឬឧបករណ៍តាមដាននៅក្នុងនោះឡើយ។ ជំនឿតៗគ្នានេះប្រហែលជាបានចាប់ផ្តើមឡើងពីការយល់ច្រឡំផ្សេងៗអំពីកំណត់ត្រាផ្នែកសុខភាពជាលក្ខណៈឌីជីថល ដែលជាតារាងព័ត៌មានផ្នែកថែទាំសុខភាពរបស់អ្នកជំងឺបែបអេឡិចត្រូនិច (ដូចជានៅក្នុងទូរស័ព្ទ ឬកុំព្យូទ័រ ជាដើម) ហើយដែលមានការរក្សាទុកដោយអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព និងមិនមានការទាក់ទងជាមួយនឹងការតាមដានបុគ្គលម្នាក់ៗនោះទេ។

**ចំណុចមិនពិត៖ អ្នកមិនត្រូវការទទួលចាក់ថ្នាំបង្ការប្រឆាំងនឹងជំងឺដែលពួកយើងបានយកឈ្នះរួចហើយនោះទេ។**
***ការពិត៖*** ខណៈដែលជំងឺមួយចំនួនគឺកម្រនឹងកើតមាននាពេលឥឡូវនេះដោយសារថ្នាំបង្ការទាំងឡាយ ប៉ុន្តែជំងឺនោះមិនបាត់ខ្លួនទាំងស្រុងនោះទេ។ ប្រសិនបើពួកយើងឈប់ទទួលចាក់ថ្នាំបង្ការ ជំងឺទាំងនេះអាចវិលត្រឡប់មកវិញយ៉ាងលឿន។ ចំណុចនេះហើយទើបពួកយើងនៅតែត្រូវការថ្នាំបង្ការ - ដើម្បីជៀសវាងជំងឺផ្សេងៗ និងការពារសហគមន៍របស់ពួកយើង ផងដែរ។

**Los Angeles County Department of Public Health**
ph.lacounty.gov/vaccines